ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D351/2/3

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៤៤)

**<u>អង្គបុរេជំនុំជម្រះ</u>**

| | | |
|---|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន | ជាប្រធាន |
| | ចៅក្រម Olivier BEAUVALLET | |
| | ចៅក្រម ន័យ ថុល | |
| | ចៅក្រម Kang Jin BAIK | |
| | ចៅក្រម ហួត វុទ្ធី | |
| កាលបរិច្ឆេទ: | ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១៧ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 09 / 2017
ម៉ោង (Time/Heure): 13:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ: កោសលុប**

**សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង**

---

**<u>សហព្រះរាជអាជ្ញា:</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្ដីម្ចាស់បណ្ដឹងឧទ្ធរណ៍</u>**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**<u>មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ចេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា

វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.T.C

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ [redacted] ចំពោះដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង" ដែលសហមេធាវីការពារក្តី [redacted] បានដាក់ ("សហមេធាវី" និង "ម្ចាស់បណ្តឹងឧទ្ធរណ៍") នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

1. បណ្តឹងឧទ្ធរណ៍នេះពាក់ព័ន្ធនឹងដីកាចេញដោយសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ដែលបញ្ជូនសំណុំរឿង ០០៤/២ នៃកិច្ចស៊ើបសួរប្រឆាំងម្ចាស់បណ្តឹងឧទ្ធរណ៍ទៅសហព្រះរាជអាជ្ញា ក្នុងគោលបំណងឱ្យចេញដីកាសន្និដ្ឋានស្ថាពរ ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")[2]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយចោទប្រកាន់ពីការចូលរួមរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅក្នុងអំពើឧក្រិដ្ឋ និងស្នើសុំឱ្យចោទប្រកាន់មកលើរូបគាត់[3]។

---

[1] បណ្តឹងឧទ្ធរណ៍របស់ [redacted] ចំពោះដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D351/2/2 ("បណ្តឹងឧទ្ធរណ៍") បានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧។ *សូមមើលផងដែរ* សំណើសុំការអនុញ្ញាតដើម្បីដាក់ជាឯកសារអង់គ្លេសជាមុននូវបណ្តឹងឧទ្ធរណ៍លើដីការបស់សហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D351/2/1។

[2] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារ D351 ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C • C.E.T.C CHAMBRE PRÉLIMINAIRE

3. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំងម្ចាស់បណ្ដឹងឧទ្ធរណ៍[4] បន្ទាប់មកបានចេញសេចក្ដីជូនដំណឹងលើកទីពីរស្ដីពីការបិទកិច្ចស៊ើបសួរនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧[5]។

4. នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៧ សហមេធាវីបានដាក់ពាក្យសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល[6] ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបដិសេធនៅក្នុងដីកាសម្រេចមួយចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៧[7]។ សហមេធាវីបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះនៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៧ ("បណ្ដឹងឧទ្ធរណ៍ស្ដីពីមោឃភាពនៃកិច្ចស៊ើបសួរ")[8]។

5. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ។ នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៧ សហមេធាវីបានដាក់សេចក្ដីជូនដំណឹងស្ដីពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ[9] និងបានដាក់សារណាលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧[10]។ សហព្រះរាជអាជ្ញាមិនបានដាក់ចម្លើយតបនៅក្នុងពេលវេលាដែលបានកំណត់ទេ។

---

4 សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង [redacted] ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ D334។

5 សេចក្ដីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង [redacted] ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D334/2។

6 ពាក្យសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារ D350។

7 ដីកាសម្រេចលើពាក្យសុំរបស់ [redacted] សុំអង្គបុរេជំនុំជម្រះពិចារណាធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារ D350/1។

8 បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចលើពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D350/1/1/2 បានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧។

9 ការជូនដំណឹងអំពីការប្ដឹងឧទ្ធរណ៍លើដីការបស់សហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារ D351/2 បានជូនដំណឹងនៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧។

10 *សូមមើល* ជើងទំព័រ ១។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

6. នៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧ អង្គបុរេជំនុំជម្រះបានបដិសេធបណ្ដឹងឧទ្ធរណ៍ស្ដីពីមោឃភាពនៃកិច្ចស៊ើបសួរ[11]។

## III. ភាពអាចទទួលយកបាន

7. សហមេធាវីលើកឡើងថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបាន យោងតាមការបកស្រាយទូលំទូលាយលើសិទ្ធិប្ដឹងឧទ្ធរណ៍តាមវិធាន ៧៤(៣) និង ២១ នៃវិធានផ្ទៃក្នុង ឬជាជម្រើសម្យ៉ាងទៀត អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងដោយផ្ទាល់[12]។ ពួកគេអះអាងថា ទោះបីច្បាប់ជាធរមានមិនបានចែងអំពីបញ្ហានានាដែលលើកឡើងក្នុងបណ្ដឹងឧទ្ធរណ៍ក៏ដោយ តែបណ្ដឹងឧទ្ធរណ៍គួរតែអាចទទួលយកបាន ដើម្បីធានានូវភាពយុត្តិធម៌នៃនីតិវិធី ភាពឆាប់រហ័ស និងការការពារសិទ្ធិជាសារវ័ន្ត ដោយសារសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ស្ដីពីមោឃភាពនៃកិច្ចស៊ើបសួរហាក់ដូចជាមានឥទ្ធិពលទៅលើយុទ្ធសាស្ត្ររបស់ភាគីក្នុងរឿងក្ដី និងខ្លឹមសារនៃដីកាសន្និដ្ឋានស្ថាពរ[13]។

8. អង្គបុរេជំនុំជម្រះសង្កេតឃើញថា បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ មិនស្ថិតនៅក្នុងយុត្តាធិការលើរឿងក្ដីរបស់អង្គជំនុំជម្រះ តាមវិធាន ៧៤ នៃវិធានផ្ទៃក្នុងទេ។ ជាងនេះទៀត ទោះបីវិធាន ២១ នៃវិធានផ្ទៃក្នុង អាចអនុញ្ញាតឱ្យអង្គជំនុំជម្រះប្រកាន់យកការបកស្រាយក្នុងន័យទូលាយអំពីសិទ្ធិប្ដឹងឧទ្ធរណ៍ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងចំពោះមុខក៏ដោយ តែវិធាននេះមិនបានផ្ដល់នូវមធ្យោបាយស្វ័យប្រវត្តិសម្រាប់បណ្ដឹងឧទ្ធរណ៍ដែលលើកឡើងពីទឡ្ហីករណ៍ផ្អែកលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឡើយ។ ម្ចាស់បណ្ដឹងឧទ្ធរណ៍ត្រូវបង្ហាញថា នៅក្នុងកាលៈទេសៈពិសេសនៃរឿងក្ដីដែលកំពុងពិនិត្យនេះ អន្តរាគមន៍របស់អង្គបុរេជំនុំជម្រះគឺជាការចាំបាច់ដើម្បីរារាំង*ព្យសនកម្មដែលមិនអាចជួសជុលបាន*

[11] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D350/1/1/4។

[12] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៧។

[13] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

ចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[14]។

9. នៅក្នុងសំណុំរឿងនេះ ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនបានបង្ហាញថា សិទ្ធិរបស់គាត់ដែលបានអះអាងអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង នឹងស្ថិតក្នុងហានិភ័យនៃការខូចខាតដែលមិនអាចជួសជុលបាន ប្រសិនបើដីកាបញ្ជូនសំណុំរឿងទៅពិនិត្យមិនត្រូវបានច្រានចោល នោះទេ។ ផលវិបាកនៃមោឃភាពកិច្ចស៊ើបសួរទាំងមូលដែលអាចមាន ពិតជាការលុបចោល និងការដកភស្តុតាងដែលត្រូវបានអះអាងថាខុសច្បាប់ចេញពីសំណុំរឿង ហេតុនេះ ជាការធានានូវសិទ្ធិជាមូលដ្ឋានរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍។ នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា សិទ្ធិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ទទួលបានភាពយុត្តិធម៌ផ្នែកនីតិវិធីនៅក្នុងដំណាក់កាលបច្ចុប្បន្ននៃកិច្ចស៊ើបសួរ ទាក់ទិននឹងខ្លឹមសារនៃដីកាសន្និដ្ឋានស្ថាពរ និងនិយមន័យនៃយុត្តិសាស្ត្រនៃការការពារក្ដីរបស់គាត់ មិនស្ថិតក្នុងហានិភ័យនៃការខូចខាតដែលមិនអាចជួសជុលបាននោះទេ ជាពិសេស ទាក់ទិននឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យដែលបានលើកឡើងយ៉ាងច្បាស់ថា គាត់ "នឹង [...] ទទួលបានពេលវេលាសមស្របដើម្បីឆ្លើយតប"[15] ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។ ក្នុងករណីណាក៏ដោយ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា បណ្ដឹងឧទ្ធរណ៍ស្ដីពីមោឃភាពនៃកិច្ចស៊ើបសួរត្រូវបានបដិសេធនៅ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧[16] ហេតុនេះ អង្គជំនុំជម្រះពិចារណាឃើញថា បញ្ហានេះត្រូវទុកជាអាសារបង់។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

- **បដិសេធ**បណ្ដឹងឧទ្ធរណ៍នេះ។

---

[14] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០៤ (អបជ ២៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D284/1/4 កថាខណ្ឌ ២១។

[15] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ កថាខណ្ឌ ១១។

[16] *សូមមើលខាងលើ* កថាខណ្ឌ ៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន Olivier BEAUVALLET ន័យ ថុល Kang Jin BAIK ហួត វុទ្ធី**